សុន្ទរកថា

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការ
ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ថ្លែងក្នុង
ពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការ ចក្ខុវិស័យនិងយុទ្ធសាស្ត្រ
ស្តីពី សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល

ថ្ងៃពុធ ១៤ កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០២២

- ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌;
- ឯកឧត្តម, លោកជំទាវ, ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, សមាជិក-សមាជិកានៃអង្គពិធី ជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំមានសេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានមកចូលរួមជាអធិបតី ក្នុងពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការ នូវ ឯកសារ «**ចក្ខុវិស័យ និង យុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល**» ដែលជាឯកសារកម្រិតគោលនយោបាយកែទម្រង់ ដ៏មានសារៈសំខាន់ សំដៅរួមចំណែកគាំទ្រដល់ការសម្រេចបាននូវ «**ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច**» ដែលជាស្នូលនៃ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤** របស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា ។

ក្នុងអាណត្តិទី ៦ នេះ, រាជរដ្ឋាភិបាលបានចាត់ទុកការងារកែទម្រង់ជាស្នូលនៃ **យុទ្ធសាស្ត្រចតុកោណ** ។ ក៏ប៉ុន្តែ, នេះមិនមែនបានន័យថា ការកែទម្រង់ទើបតែត្រូវបានចាប់ផ្តើមនោះឡើយ; ផ្ទុយទៅវិញ, រាជរដ្ឋាភិបាល, ក្រោមការដឹកនាំដ៏ត្រឹមត្រូវ ប្រកបដោយភាពឈ្លាសវៃ និង ភាព-

ប្រាកដនិយមខ្ពស់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, បានចាប់យកការកែទម្រង់ធ្វើជាយុទ្ធសាស្ត្រគន្លឹះ នៅក្នុងការដឹកនាំស្តារ និង កសាងជាតិ អស់រយៈពេលរាប់ទសវត្សរ៍មកហើយ ។

ជាការពិត, ការងារកែទម្រង់នៅកម្ពុជា បានក្លាយជាស្នូលនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចតាំងពីក្នុងគ្រាដែលកម្ពុជាទើបរួចចាកផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត នាថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧៩ មកម្ល៉េះ ដែលពេលនោះ អាទិភាពចាំបាច់ទីមួយរបស់យើង គឺបញ្ចប់ការអត់ឃ្លាន, ហើយគោលដៅសំខាន់បំផុតនៃការកសាងជាតិឡើងវិញ គឺ **ការរកដំណោះស្រាយបញ្ចប់ភាពទុរភិក្សរបស់ប្រជាជនយើង** ។ ជាបន្តបន្ទាប់, រដ្ឋាភិបាលនៃអតីតសាធារណរដ្ឋប្រជាមានិតកម្ពុជា, និង ក្រោយមកទៀត, រដ្ឋកម្ពុជា, បានដាក់ចេញ និង ជំរុញអនុវត្តយ៉ាងសកម្ម, ប្រកបដោយភាពក្លាហានមោះមុតឥតរាថយ, នូវវិធានការកែទម្រង់មុតស្រួច, ពិសេស, ការផ្លាស់ប្តូររបបកម្មសិទ្ធិ តាមរយៈការ-ផ្តល់កម្មសិទ្ធិដីធ្លីជូនប្រជាជន សំដៅធ្វើបរិវត្តកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ច ពី **«ប្រព័ន្ធសេដ្ឋកិច្ចផែនការ»** ជាជំហានៗ ទៅជា **«ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារប្រជាជន»** ។ ចំណុចនេះអាចទុកជាការបកស្រាយមួយទៅលើប្រវត្តិនៃទិសស្លោកគន្លឹះ ដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** តែងតែបានផ្តល់ឱវាទានុសាសន៍រំលឹកជាប់ជាប្រចាំដល់យើងទាំងអស់គ្នាថា «**កែទម្រង់ រស់**, **មិនកែទម្រង់ស្លាប់**» ។

ក្នុងសម័យសន្តិភាព, ថ្វីត្បិតអាទិភាពនៃការកែទម្រង់របស់យើង មានការផ្លាស់ប្តូរទៅតាមតម្រូវការនៃសង្គមដែលកំពុងអភិវឌ្ឍលូតលាស់, ទិសស្លោកគន្លឹះមួយនេះ នៅតែជាគំនិតដឹកនាំដ៏ត្រឹមត្រូវ និង ប្រកបដោយសច្ចធម៌ ដែលខ្ញុំយល់ថា ថ្នាក់ដឹកនាំ និង មន្ត្រីរាជការសាធារណៈគ្រប់លំដាប់ថ្នាក់ ត្រូវស្វែងយល់ និង រក្សាទុក, ជាពិសេស ត្រូវចៀសវាងសេចក្តីយល់ខុសថា ការងារកែទម្រង់ គឺជាការបន្ថែមបន្ទុកលើការបំពេញមុខងារ និង ភារកិច្ចប្រចាំថ្ងៃរបស់ខ្លួន ។

ជាសត្យានុម័ត, រដ្ឋាភិបាលនៃប្រទេសនីមួយៗ តែងមាននូវបញ្ជីអាទិភាពសម្រាប់ការ-កែទម្រង់ទៅតាមរបៀបវារៈគោលនយោបាយ និង តាមវិធីសាស្ត្រដោយឡែកពីគ្នា អាស្រ័យលើបរិបទសង្គម, ប្រពៃណីស្ថាប័ន និង បែបបទរដ្ឋបាលរៀងៗខ្លួន ។ សម្រាប់កម្ពុជា, យើងបានរៀបចំការងារកែទម្រង់ជាកម្មវិធីរយៈពេលវែង ដោយមានការកំណត់ចក្ខុវិស័យវែងឆ្ងាយ និង មានការបែងចែកជាដំណាក់កាល ប្រកបដោយភាពប្រាកដនិយម និង គោលដៅជាក់លាក់ ព្រមទាំងមានរចនាសម្ព័ន្ធដឹកនាំ និង យន្តការអនុវត្តច្បាស់លាស់ ។ វិធីសាស្ត្រនេះ បានបង្ហាញអំពីសេចក្តី-ក្លាហាន, មហិច្ឆតា និង ឆន្ទៈមោះមុតរបស់យើង លើការកែទម្រង់ ដែលអាចអនុវត្តទៅបានតាម

បរិបទកម្ពុជា និង ឆ្លើយតបបានទៅតាមសេចក្ដីត្រូវការរបស់កម្ពុជា ប្រកបដោយមោទនភាព, ប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព ។

ផ្អែកលើទស្សនៈវិស័យនេះ, រាជរដ្ឋាភិបាលបានដាក់ចេញជាកម្មវិធីកែទម្រង់រយៈពេលវែងជាច្រើន លើគ្រប់វិស័យ, ពិសេស កម្មវិធីកែទម្រង់ពាក់ព័ន្ធនឹងការបង្កើនគុណភាពអភិបាលកិច្ច ឬ ការកែទម្រង់លើរចនាសម្ព័ន្ធ ឬ អាចហៅម្យ៉ាងទៀតថា ការកែទម្រង់ដែលមានលក្ខណៈជាប្រព័ន្ធ ដែលមាន **ចំនួន ៤ សំខាន់ៗ** គឺ៖ **១.កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**; **២.កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**; **៣.កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ** និង **៤.កម្មវិធីកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌** ។ កម្មវិធីកែទម្រង់នីមួយៗខាងលើនេះ មានរចនាសម្ព័ន្ធដឹកនាំ, យន្តការអនុវត្ត និង ផែនការសកម្មភាពយ៉ាងលម្អិត រហូតទទួលបានការ-សាទរ និង ការគាំទ្រពីដៃគូអភិវឌ្ឍន៍នានា រួមមានទាំងការផ្ដល់ជំនួយបច្ចេកទេស និង ហិរញ្ញវត្ថុជាបន្តបន្ទាប់ ក្នុងភាពជាដៃគូ, កិច្ចសហប្រតិបត្តិការ និង ការគោរពភាពជាម្ចាស់របស់កម្ពុជា ។

ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

កម្មវិធីកែទម្រង់ទាំង ៤ នេះ បានវិវត្តរីកចម្រើនទៅមុខ ដោយស្រង់បាននូវបទពិសោធន៍ជាមេរៀនល្អៗយ៉ាងច្រើន និង ជាមូលដ្ឋានគន្លឹះនៃការកែទម្រង់កម្មវិធីរបស់ខ្លួន សម្រាប់ដំណាក់-កាលបន្តបន្ទាប់ទៀត ។ ក្នុងន័យនេះ, **កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** បានចាប់ផ្ដើមកម្មវិធីជាតិ ១០ ឆ្នាំ លើកទី ១ (២០១០-២០១៩) របស់ខ្លួន មុននឹងបោះជំហានមកដល់កម្មវិធីជាតិ ១០ ឆ្នាំលើកទី ២ (២០២១-២០៣០) ដែលទើបត្រូវបាន ចាប់ផ្ដើមកាលពីពេលថ្មីៗ ។ **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ត្រូវបានចាប់ផ្ដើមជាផ្លូវការ នៅក្នុងឆ្នាំ ២០០៤ និង ត្រូវបានកំណត់ថា ត្រូវអនុវត្តរហូតដល់ឆ្នាំ ២០២៥ ដោយចែកជា ៤ ដំណាក់កាល ។ បច្ចុប្បន្ន, **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** កំពុងស្ថិតក្នុងដំណាក់កាលអន្តរកាល ៣ បូក ២ មុននឹងទៅចាប់ផ្ដើមជាផ្លូវការនូវ ដំណាក់កាលទី ៤ ដែលជាដំណាក់កាលចុងក្រោយ ផ្ដោតលើការសម្រេចបាននូវ **«គណនេយ្យភាពសមិទ្ធកម្ម»** ។ ដោយឡែក, **កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ** ដំណាក់កាលទី ១ (២០១៥-២០១៨) ត្រូវបានបញ្ចប់រួចរាល់ ហើយកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២២-២០៣៥ កំពុងតែត្រូវបានរៀបចំដើម្បីដាក់ឱ្យអនុវត្តជាបន្ត ។ រីឯ **កម្មវិធីកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌** ក៏កំពុងត្រូវបានរៀបចំជារចនាសម្ព័ន្ធដឹកនាំ និង យន្តការអនុវត្តរស់រវើក ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

បច្ចុប្បន្ន, នៅក្នុងជំហានចុងក្រោយ នៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤** ដែលមាន «**ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច**» ជាស្នូល, រាជរដ្ឋាភិបាលកម្ពុជា, តាមរយៈគណៈកម្មាធិការដឹកនាំការងារកែទម្រង់ទាំង ៤, បានបោះជំហានជាប្រវត្តិសាស្ត្រមួយកម្រិតទៀត នោះគឺការធានាសុខដុមនីយកម្មនៃការកែទម្រង់ទាំងនេះ ឱ្យមានសង្គតិភាព, ប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព ដើម្បីបម្រើឱ្យគោលបំណងដ៏ចម្បងបំផុតរបស់ខ្លួន ពោលគឺការឆ្លើយតបសំណូមពររបស់ប្រជាពលរដ្ឋ ឱ្យបានកាន់តែប្រសើរ ។

នៅក្នុងបរិបទសកលលោកបច្ចុប្បន្ននេះ, ការកែទម្រង់ផ្នែកអភិបាលកិច្ចមានសារៈសំខាន់ជាងពេលណាៗទាំងអស់ ព្រោះយើងត្រូវពង្រឹងសមត្ថភាព និង ភាពរឹងមាំរបស់ស្ថាប័នសាធារណៈ ក្នុងការឆ្លើយតបតាមរយៈវិធានការបង្ការជាបុរេសកម្ម បានទាន់ពេល និង ប្រកបដោយប្រសិទ្ធភាព ចំពោះវិបត្តិជាច្រើន ដែលអាចកើតឡើងដោយមិនអាចស្មានទុកបាន និង កាន់តែពិបាកដោះស្រាយ ព្រមទាំងមានលក្ខណៈកាន់តែស្មុគស្មាញខ្លាំងឡើង ។ ជាក់ស្តែង, យើងបាន និង កំពុងទទួលរងគ្រោះពីវិបត្តិជាសកល ឬ វិបត្តិកើតចេញពីកត្តាខាងក្រៅជាច្រើន ដែលសកលលោកមិនធ្លាប់ ឬកម្រជួបប្រទះ ដូចជា វិបត្តិនៃជំងឺកូវីដ-១៩ និង វិបត្តិនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ។ បន្ថែមលើនេះ, រាជរដ្ឋាភិបាលក៏ត្រូវគិតគូរប្រឹងប្រែងពង្រឹងសមត្ថភាពរបស់ខ្លួនថែមទៀតផងដែរ នៅក្នុងក្របខណ្ឌនៃការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យបច្ចេកវិទ្យា ក្នុងយុគសម័យបដិវត្តឧស្សាហកម្ម ៤.០ ។

ឯកសារ **ចក្ខុវិស័យ និង យុទ្ធសាស្ត្រ ស្តីពីសុខដុមនីយកម្មនៃការកែទម្រង់ ៣ បូក ១** នេះ មានគោលបំណងធានាសុខដុមនីយកម្មនៃការកែទម្រង់ ដោយយកសមិទ្ធផល និង បទពិសោធន៍កន្លងមក ធ្វើជាមូលដ្ឋានឈានឆ្ពោះទៅសម្រេចបាន នូវគោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដោយត្រូវឆ្លើយតបទៅនឹងសភាពការណ៍វិវត្តនៃបរិបទសកលលោក ។

ក្នុងន័យនេះ, ដើម្បីសម្រេចបាននូវ **ចក្ខុវិស័យ «សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១» និង បេសកកម្ម «ធានាសង្គតិភាព និង ស័ក្តិសិទ្ធភាពនៃការគ្រប់គ្រង និង ការសម្របសម្រួលកម្មវិធីកែទម្រង់ ៣ បូក ១»**, ខ្ញុំសូមផ្តល់ជូនជាអនុសាសន៍ ឬ អភិក្រមចំនួន ៤ ដែលផ្តោតជាពិសេសលើការអនុវត្តការងារកែទម្រង់របស់យើង ដូចតទៅ៖

ទី១. អភិក្រមរក្សាគំហើញទាំងមូល ដែលសំដៅដល់ប្រការដែលកម្មវិធីកែទម្រង់មួយត្រូវពឹងផ្អែក និង អាស្រ័យលើកម្មវិធីកែទម្រង់មួយទៀត ដោយប្រទាក់ក្រឡាគ្នា និង មានទំនាក់-ទំនងដោយមិនអាចខ្វះបាន នៅក្នុងបរិយាកាសរួមនៃការកែទម្រង់ ។ ឧទាហរណ៍, ការផ្ទេរមុខងារតម្រូវឱ្យពិនិត្យ និង រៀបចំជាវិធាន និង នីតិវិធីជាកញ្ចប់ក្នុងពេលតែមួយ ជាមួយនឹងការផ្ទេរ

ធនធានហិរញ្ញវត្ថុ និង ធនធានមនុស្ស, ក៏ដូចជាការពិនិត្យទិដ្ឋភាពក្របខណ្ឌស្ថាប័ន, ច្បាប់ និង នីតិវិធី, និង ប្រព័ន្ធយុត្តិធម៌ ។ល។

ទី២. អភិក្រមចូលរួមចំណែកតាមតួនាទី សំដៅដល់៖ កម្មវិធីកែទម្រង់នីមួយៗ ត្រូវបំពេញឱ្យគ្នាមិនអាចខ្វះបាន, ទៅតាមតួនាទី និង សមត្ថកិច្ច, នៅក្នុងក្របខណ្ឌនៃមុខងារស្ថាប័នរៀងៗខ្លួន ដែលត្រូវបានកំណត់ដោយច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

ទី៣. អភិក្រមរក្សាភាពជាម្ចាស់ និង គាំទ្រកិច្ចសហការ គឺការគោរពភាពជាម្ចាស់លើវឌ្ឍនភាព និង គណនេយ្យភាពចំពោះកម្មវិធីកែទម្រង់របស់ខ្លួនផង និង ការផ្តល់ការគាំទ្រ និង កិច្ចសហការប្រកបដោយឆន្ទៈ ជាមួយនឹងកម្មវិធីកែទម្រង់ផ្សេងទៀត ។

ទី៤. អភិក្រមបុរេសកម្ម គឺការត្រៀមលក្ខណៈដោះស្រាយបញ្ហា ឬ ទប់ស្កាត់បញ្ហាមិនឱ្យកើតមាន តាមរយៈយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ ដោយមិនរង់ចាំបញ្ហាកើតឡើងទើបចាប់ផ្តើមធ្វើសកម្មភាពនោះឡើយ ។

ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

មុននឹងបញ្ចប់, ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ និង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះថ្នាក់ដឹកនាំ និង មន្ត្រីរាជការនៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការ-អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, លេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និង លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដែលបានសហការ, សម្របសម្រួល និង សម្រេចបាន នូវលទ្ធផលគួរជាទីមោទនៈនេះ ប្រកបដោយស្មារតីសាមគ្គីភាព និង សុឆន្ទៈខ្ពស់ ក្នុងការងារកែទម្រង់ ។ ខ្ញុំក៏សូមថ្លែងអំណរគុណ និង កោតសរសើរចំពោះឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាថ្នាក់ដឹកនាំ និង មន្ត្រីរាជការនៃក្រសួង-ស្ថាប័ន, រដ្ឋបាលថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដែលកន្លងមក បានផ្តល់មតិយោបល់កែលម្អស្ថាបនា នូវឯកសារចក្ខុវិស័យនេះ រហូតដល់សម្រេចបានលទ្ធផលដ៏គាប់ប្រសើរនាថ្ងៃនេះ ។

ខ្ញុំសូមលើកទឹកចិត្តដល់សមាជិក-សមាជិកានៃអង្គពិធី ដែលប្រព្រឹត្តទៅរយៈពេលពេញមួយថ្ងៃនេះ ប្រើប្រាស់បញ្ញាស្មារតីឱ្យអស់សក្តានុពល ចូលរួមក្នុងកិច្ចពិភាក្សាតាមក្រុមឱ្យបានផុសផុល ដែលនឹងផ្តោតលើចំណុចប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំង ៤ នៅតាមក្រសួង

ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើអាទិភាវូបនីយកម្មបញ្ហាដែលត្រូវដោះស្រាយតាមរយៈយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ នេះ **ដោយមិនយកភាពឥតខ្ចោះធ្វើជាឧបសគ្គនោះឡើយ គឺត្រូវប្រកាន់អភិក្រម «ធ្វើបណ្ដើរ, រៀនបណ្ដើរ» និង សម្លឹងឆ្ពោះទៅមុខនូវគោលដៅជាក់លាក់ ក្នុងស្មារតីតម្កល់សមិទ្ធកម្មជាត្រីមុខ** ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, បានប្រកបដោយសុខភាពល្អ, សំណាងល្អ, សុភមង្គល និង សម្រេចបានជោគជ័យក្នុងគ្រប់កិច្ចការរបស់ខ្លួន ។

ខ្ញុំសូមប្រកាស **បើកពិធីដាក់ឱ្យប្រើជាផ្លូវការ** នូវ **ចក្ខុវិស័យ និង យុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១** ចាប់ពីពេលនេះតទៅ ។

សូមអរគុណ !